សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥៩

ចុះថ្ងៃទី ១២.០១.២០០៩

ជំនុំជំរះលេខ ១៩៦១

ចុះថ្ងៃទី ១៤.១២.២០០៩

សាលក្រមព្រហ្មទណ្ឌ

លេខ ៤៨ ក្រ៦ "ជ"

ចុះថ្ងៃទី ១២.៥.២០១១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសធារណៈ នៅសាលជំនុំជំរះក្តីនៃសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ៨H០០ នាទី ដោយមានសមាសភាពដូចតទៅ ៖

### ក្រុមប្រឹក្សាជំនុំជំរះ

.លោក[redacted]ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

.លោក[redacted]ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

.លោ[redacted]ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

.លោក[redacted]ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

.លោក[redacted]ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៩ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ[redacted]ហៅ ផា ភេទ ប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិចំការស្បែង សង្កាត់សំរោងក្រោម ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិចំការស្បែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុក[redacted] ម្តាយឈ្មោ[redacted]នៅ លើរ ទោសពីមុន គ្មាន ។

ឃាត់ខ្លួនថ្ងៃទី ១១.៣.២០១០ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨៥ ត.ព្រ ចុះថ្ងៃទី ១៥.៣.២០១០។

មេធាវីការពារជនជាប់ចោទ លោ[redacted]

២.ឈ្មោះ[redacted]ហៅ[redacted]ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោ[redacted]ម្តាយឈ្មោះ[redacted]) ប្រពន្ធឈ្មោះ[redacted]នកូន ០១ នាក់ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]

៣.ឈ្មោ[redacted]ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោ[redacted]ម្តាយឈ្មោ[redacted]នៅលើរ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]



Scanned by CamScanner

៤.ឈ្មោះ[redacted]ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted]ម្តាយឈ្មោះ[redacted]) នៅលីវ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]

៥.ឈ្មោះ[redacted]ប្រុស អាយុ ២៤ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted]ម្តាយឈ្មោះ[redacted]នៅលីវ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]

៦.ឈ្មោះ [redacted]ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted]ម្តាយឈ្មោះ[redacted]នៅលីវ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]

៧.ឈ្មោះ[redacted]ហៅ រាជ ភេទប្រុស អាយុ[redacted] ជាតិខ្មែរ ទីកន្លែងកំណើតភូមិចំការស្បែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញភ្នំពេញ មុខរប[redacted]ប្បន្នភូមិចំការស្បែង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ។

មេធាវីការពារជនជាប់ចោទ លោក[redacted]

ជាប់ចោទពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១.១២.២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ភេទស្រី អាយុ៣៥ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិត្រពាំងធ្នង់ ឃុំសំរោង ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ផ្លូវកប់ស្រូវ ភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ[redacted]

មេធាវីការពារជនជាប់ចោទ លោក[redacted]និងលោក[redacted]

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២០៤៧ អ.យ.ខ ចុះថ្ងៃទី ១០.១១.២០០៩ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ២០៧៥៨ ត.ព្រ ចុះថ្ងៃទី ០៩.១២.២០០៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

## ដំណើររឿងមានដូចតទៅ÷

តាមរបាយការណ៍សំយោគលេខ ០២/០៩ ចុះថ្ងៃទី ០២.០១.២០០៩ របស់ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់ និងពាក្យបណ្តឹងរបស់ជនរងគ្រោះឈ្មោះ[redacted] ១៧.១២.២០០៨ ដែលបានប្តឹងពីឈ្មោះ[redacted]ងឈ្មោះ [redacted]ទាំងបក្សពួក០៥នាក់ បានធ្វើសកម្មភាពបួនវាយប្តីឈ្មោះ [redacted]ស្លាលអោយស្លាប់និងយកសំភារៈ



Scanned by CamScanner

មួយចំនួន។ ក្រោយពីសមត្ថកិច្ចធ្វើការ [redacted] ានចំនួន០៧នាក់ គឺមានឈ្មោះ [redacted]

**នាពេលសវនាការ**

.ជនជាប់ចោទឈ្មោះ [redacted] ខ្ញុំស្គាល់ដោយសាររស់នៅ [redacted] ។ នៅថ្ងៃកើតហេតុ ខែ ១២ ឆ្នាំ ២០០៨ ខ្ញុំបានផឹកស្រាបៀរជាមួយឈ្មោះ [redacted] ផឹកនៅផ្ទះតាកៅ ចាប់ផ្ដើមពីម៉ោង ៦H00 នាទីល្ងាច រហូតដល់ម៉ោង ៩H00 នាទយប់ ហើយក៏បន្តទៅផឹកជាមួយឈ្មោះ [redacted] នៅឃ្លាំងរហូតដល់ម៉ោង ១២H00 នាទីយប់ ។ ពេលពួកខ្ញុំបន ហូបស្រាបៀរនេះ មានគ្នា៦នាក់ គឺខ្ញុំបាន [redacted] មិនបានចូលរួមផឹកជាមួយពួកខ្ញុំទេ ម្ដាយរបស់គេជាអ្នកលក់ខ្សាច់លកសុមង។ ពួកខ្ញុំទាំង៦នាក់នេះ ជិះម៉ូតូពីរគ្រឿងម៉ាកស្ពេប ផឹកហើយក៏ដេកយាមឃ្លាំង ត្រែមួយទាំងអស់គ្នា ហើយជជែកគ្នាពីរឿងលែងបាល់ ស្រាប់តែឮសូរផ្ទុះគ្រាប់កាំភ្លើង ពួកខ្ញុំស្មានតែផ្ទុះកង់ឡាន។ លុះព្រឹកឡើង ទើបខ្ញុំដឹងថាពីកន្លែងកើតហេតុមក កន្លែងឃ្លាំងដែលពួកខ្ញុំសំរាកមានចម្ងាយប្រហែល ៤០០ម៉ែត្រ។ ឈ្មោះ [redacted] ាត់ជាអ្នករស់នៅក្នុងភូមិជាមួយគ្នា គាត់ធ្វើប៉ូលីសត្រូវបានគេប្លន់ម៉ូតូកាលពីយប់ ហើយខ្ញុំក៏បានមកធ្វើជាជាងជួសជុលឡានប្រហែលរយៈពេលមួយខែ ខ្ញុំឮគេថាខ្ញុំនិងបក្សពួកជាជនដៃដល់ក្នុងករណីប្លន់ម៉ូតូ ខ្ញុំខ្លាចគេចាប់ ក៏រត់ទៅខេត្តរតនៈគីរី លុះពេលខ្ញុំត្រលប់មកផ្ទះវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ។ សំណូមពរសុំអោយតុលាការលើកលែងចោទប្រកាន់ ពីព្រោះខ្ញុំពុំបានប្រព្រឹត្តអំពើប្លន់សំលាប់ជនរងគ្រោះទេ ។

.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ [redacted] ានបំភ្លឺថា៖ នៅថ្ងៃទី ១១.១២.២០០៨ មាននគរបាលប៉ុស្ដិ៍សំរោងក្រោមពីរនាក់ ម្នាក់ឈ្មោ [redacted] ម្នាក់ទៀតមិនស្គាល់ឈ្មោះបានមកប្រាប់ខ្ញុំថា មានចោរប្លន់ប្ដីនៅខាងត្បូងភូមិ ដោយមានចោរមួយក្រុមវាយរបួសយ៉ាងធ្ងន់ធ្ងរ ។ ពេលប៉ូលីសប្រាប់នេះ គេបានដឹកប្ដីខ្ញុំទៅដល់មន្ទីរពេទ្យជិតសង្កាត់ចោមចៅ។ លុះព្រឹកឡើង នាងខ្ញុំបានដឹកប្ដីទៅមន្ទីរពេទ្យកាល់ម៉ែត្រ ព្យាបាលរយៈពេល៦ថ្ងៃ ក៏បានស្លាប់នៅថ្ងៃទី ១៦.១២.២០០៨ ។ ក្រោយពីប្ដីខ្ញុំស្លាប់ ខ្ញុំពិនិត្យប្ដីឃើញស្នាមវ៉ៃទីងដែកជន្ទៀសឡានជាច្រើនកន្លែងជាំខ្មៅ ជាំពីត្រចៀករហូតដល់ក ក្បាលផុងគ្រប់កន្លែងទាំងអស់។ នាងខ្ញុំទាមទារ សំណងជម្ងឺចិត្តចំនួន ២០០,០០០$ (ម្ភៃម៉ឺនដុល្លារអាមេរិក) ពីជនជាប់ចោទឈ្មោះ [redacted] និងសុំអោយផ្ដន្ទាទោសជនជាប់ចោទអោយបានធ្ងន់ធ្ងរបំផុត។

.សាក្សីឈ្មោះ [redacted] ានបំភ្លឺថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ ខ្ញុំមិនបាននៅកន្លែងកើតហេតុទេ។ ក្រោយមកនៅថ្ងៃទី១២.១២.២០០៨ វេលាម៉ោងប្រហែល ១៤H00 នាទី មានប៉ូលីសសំរោងក្រោមម្នាក់ឈ្មោ [redacted] ាប់ថានៅពេលគេប្លន់យកទ្រព្យសម្បត្តិ និងវាយឈ្មោះ [redacted] ាត់បានដេញបាញ់គំរាមឡើងលើប្រហែល ១៧គ្រាប់ ហើយឈ្មោ [redacted] ប្រាប់ថារកឃើញមុខសញ្ញាហើយ ហើយអោយខ្ញុំសរសេរពាក្យបណ្ដឹងទៅដាក់មេប៉ុស្ដិ៍ [redacted] ឈ្មោះខ្ញុំជាអ្នកសរសេរចំនួន ៧នាក់ [redacted] ។ នៅថ្ងៃទី ២៤.១២.២០០៨ [redacted] អោយខ្ញុំជួយសំរួលជាមួយឈ្មោះ [redacted] ប្រពន្ធជនរងគ្រោះអោយដកពាក្យបណ្ដឹង ឈប់ប្ដឹងអោយដោះស្រាយជាសំណងទៅ ខ្ញុំក៏ប្រាប់ទៅ [redacted] ញថា ចាំខ្ញុំសួរប្អូនសិន ហើយឈ្មោ [redacted] ទទូរសព្ទ័។



Scanned by CamScanner

សាក្សីឈ្មោះ [redacted] បានបំភ្លឺថា៖ ខ្ញុំរក្សាចម្លើយដដែល ហើយសុំបំភ្លឺនាពេលសវនាការថា កាលពីថ្ងៃទី ១១.១២.២០០៨ វេលាម៉ោង ១H00យប់ ខ្ញុំកំពុងយាមប្រចាំការ មានមនុស្សពីរនាក់មកប្តឹងដល់ប៉ុស្តិ៍ថា មានមនុស្សដួលសន្លប់ ។ ពេលនោះពួកខ្ញុំបួននាក់មានខ្ញុំបាទ [redacted] បានចេញទៅដោយជិះម៉ូតូបានប្រហែល ២០០ម៉ែត្រ ឃើញជនសង្ស័យមួយក្រុម មិនដឹងចំនួន។ ខណៈនោះ មានជនសង្ស័យ ពីរនាក់ជិះម៉ូតូ C១២៥ ពណ៌ខ្មៅ ចេញពីកន្លែងកើតហេតុយ៉ាងលឿន រីឯជនសង្ស័យផ្សេងទៀត រត់គេចខ្លួនអស់ ពួកខ្ញុំក៏បានជិះម៉ូតូដេញតាម ហើយបាញ់ឡើងលើអោយជនសង្ស័យឈប់ ពេលនោះជនសង្ស័យបានផ្តួលម៉ូតូចោល រត់គេចខ្លួនបាត់តែម្តង។ ខ្ញុំនិងឈ្មោះ [redacted] បានយកម៉ូតូទុកនៅប៉ុស្តិ៍។ នៅថ្ងៃទី ១៤.១២.២០០៨ វេលាម៉ោង ១១H00 នាទី ឈ្មោះ [redacted] នទូរស័ព្ទមកខ្ញុំពីរដង អោយមកផ្ទះជនរងគ្រោ [redacted] បន្ទាប់មកឈ្មោះ [redacted] បានយកក្រដាសសរសេរដៃ មកឃើញមានឈ្មោះជនសង្ស័យ៧នាក់អោយខ្ញុំមើល។ ចំពោះអាវជាភស្តុតាងខ្ញុំអត់បានយកមកទេ។

សាក្សីឈ្មោះ [redacted] នបំភ្លឺថា៖ កាលពីថ្ងៃខែឆ្នាំ មិនចាំ វេលាម៉ោង ៨ព្រឹក ជាងខ្ញុំបានជិះកង់មករកហូមកាហ្វេ ពេលមកដល់កំពង់ថ្ម ខ្ញុំរើសបានដែកជញ្ជាសឡាននៅតំនរថ្ម ហើយខ្ញុំនិយាយប្រាប់គេថា ខ្ញុំរើសបានដែក។ លុះព្រឹកឡើងឈ្មោះ [redacted] មកសួរហើយបានសុំ ខ្ញុំក៏អោយ ខ្ញុំអត់បានឃើញស្នាមឈាមប្រឡាក់ដែកជញ្ជាសឡាននោះទេ រឿងអ្វីផ្សេងទៀតខ្ញុំក៏អត់ដឹងដែរ។

សាក្សីឈ្មោះ [redacted] បានបំភ្លឺថា៖ ថ្ងៃកើតហេតុ ថ្ងៃខែឆ្នាំ ខ្ញុំអត់ចាំទេ ។ វេលាម៉ោងប្រហែល ១H00 យប់ ខ្ញុំមកពីបង់ត្រី បានជួបមនុស្សម្នាក់រងគ្រោះនៅតំនរថ្ម ឃើញបិទភ្នែក ខ្ញុំរៀបជួយ ប៉ុន្តែបានឃើញមនុស្សពីរនាក់មកដល់ ហើយស្រែកថាងាកចេញៗ ហើយខ្ញុំក៏បានទៅរាយការណ៍ប្រាប់ប៉ូលីស ។ ខ្ញុំមិនស្គាល់មនុស្សពីរនាក់នោះទេ ប៉ុន្តែខ្ញុំឃើញជិះម៉ូតូស្វាស។ ខ្ញុំបានរាយការណ៍ប្រាប់ប៉ូលីសពីហេតុការណ៍អ្វីដែលខ្ញុំបានឃើញ ជនរងគ្រោះដេកលើតំនរថ្ម ហើយម៉ូតូដួលនៅជិតនោះ ប្រហែល ៣ រឺ ៤ម៉ែត្រ ។

សាក្សីឈ្មោះ [redacted] នបំភ្លឺថា៖ អ្នកស្លាប់នៅស្រុកជាមួយខ្ញុំ ខ្ញុំឃើញប៉ូលីស ហើយពួគេនិយាយថាប៉ូលីសឈ្មោះ [redacted] អ្នកបាញ់ ហើយចោរបានផ្តួលម៉ូតូចោល ប៉ូលីសក៏យកម៉ូតូទៅទុកនៅប៉ុស្តិ៍ ។ [redacted] ខ្ញុំស្គាល់ ។ [redacted] នជិះម៉ូតូមកពីខាងជើង ហើយឈ្មោ [redacted] នស្រែកថាជនរងគ្រោះស្លាប់បាត់ហើយ។

សាក្សីឈ្មោ [redacted] បានបំភ្លឺថា៖ ថ្ងៃកើតហេតុខ្ញុំអត់ចាំទេ ។ យប់នោះឈ្មោ [redacted] ខ្ញុំតាំងពីព្រលប់រហូតដល់ម៉ោង ១១H00យប់ ខ្ញុំក៏អោយទៅផ្ទះ [redacted] ផ្ទះប្រហែលកន្លះម៉ោង ស្រាប់តែឮស្នូរគ្រាប់កាំភ្លើង។ [redacted] អ្នកភូមិជិតគ្នា។ នៅយប់នោះឈ្មោះ [redacted] ផ្ទះខ្ញុំ ទៅចាប់ត្រីអន្ទង់ជាមួយខ្ញុំ លុះប្រហែលនៅម៉ោង ១១H00យប់ ខ្ញុំក៏ដេញទៅផ្ទះ។

សាក្សីឈ្មោះ [redacted] បានបំភ្លឺថា៖ នៅថ្ងៃកើតហេតុខ្ញុំអត់ចាំទេ។ [redacted] នៅយប់ថ្ងៃកើតហេតុ ខ្ញុំបានហូបស្រាបៀរជាមួយឈ [redacted] ឈ្មោះ [redacted] ហូបនៅផ្ទះខ្ញុំ យប់បន្តិចក៏នាំគ្នាទៅហូប [redacted] រហូតដល់ម៉ោងប្រហែល ១H00យប់។ អ្នកទៅផ្ទះមានឈ្មោ [redacted] ក្រៅពីនេះនៅផ្ទះពូខ្ញុំទាំងអស់។ ហើយក៏ឮស្នូរគេបាញ់ប្រហែលម៉ោង ១២H00យប់ ពីផ្ទះពូខ្ញុំទៅកន្លែងកើតហេតុប្រហែល ១០០ម៉ែត្រ ឈ្មោះ [redacted] បានចេញទៅផ្ទះនៅម៉ោងប្រហែលនៅម៉ោង ៧H00យប់ ឈ្មោះ [redacted] នបានចូលរួមហូបចុកជាមួយពួកខ្ញុំទេ ឈ្មោះ [redacted] ចេញទៅផ្ទះ ៦នាក់ទៀតហូបនៅផ្ទះពូខ្ញុំ អស់ស្រាបៀរប្រហែល៤កេះ ។ យប់នោះហូបក្នុងឌីឡូតិ៍ពូរបស់ខ្ញុំ ពុំមានអ្នកណាចេញទៅណាទេ ។



Scanned by CamScanner

74/7

សាក្សីលោក [redacted] បានបំភ្លឺថា៖ យប់ថ្ងៃកើតហេតុខ្ញុំនៅផ្ទះ លុះព្រឹកឡើងម៉ោងប្រហែល ៩H00 ១០H00 ខ្ញុំឮគេនិយា[redacted] យប់មិញមានករណីប្លន់ម៉ូតូ មាន[redacted]អ្នកធ្វើសកម្មភាព បន្ទាប់មកខ្ញុំក៏ជិះម៉ូតូល្បាតតាម[redacted]ចេញពីផ្ទះទាំងអស់។ ប្រហែល៣ រឺ៤ថ្ងៃ ឃើញឈ្មោះ [redacted] អោយដាក់ពាក្យបណ្តឹងប្តឹងអ្នកទាំង៧នាក់ ដើម្បីដោះស្រាយគ្នាបានលុយខ្លះដោះស្រាយថ្នាំពេទ្យ។ ខ្ញុំមិនដឹងឈ្មោះ [redacted] បានឈ្មោះទាំង៧នាក់នោះមកពីណាទេ ដោយសារតែមានក្មួយគាត់ពីរនាក់ឈ្មោ[redacted]គត់ហ៊ានធ្វើសាក្សីអោយគាត់ស្អប់ណាស់ ។ ការគ្រោះថ្នាក់ចរាចរខ្ញុំឥតគិតអញ្ជឹងទេ អាវឃើតមេប៉ូលីសអោយខ្ញុំទៅយកពីឈ្មោះ [redacted] ពាក់។ ពេលកើតហេតុប្រហែលពី បីថ្ងៃ ឃើញគេយកសាកសពមកផ្ទះ។ ខ្ញុំឮគេនិយាយថាមានស្នាមគេវៃ ខ្ញុំឃើញតែស្នាមជាំនៅកញ្ជឹងក ពុំឃើញមានអ្វីទៀតទេ។ ខ្ញុំបានធ្វើរបាយការណ៍ថា ជាគ្រោះថ្នាក់ចរាចរណ៍ [redacted] អោយធ្វើរបាយការណ៍ ខ្ញុំមិនបានធ្វើលិខិតបដិសេធទីរបាយការណ៍របស់ខ្ញុំទេ។ [redacted]អ្នកអោយសរសេរឈ្មោះទាំង៧នាក់ ខ្ញុំបាទមិនបានចុះវាស់វែង កន្លែងគ្រោះថ្នាក់ចរាចរណ៍នោះទេ ។

សាក្សីឈ្មោះ [redacted]បានបំភ្លឺថា៖ ដំបូងថ្នាក់លើជាអ្នកអោយខ្ញុំធ្វើរបាយការណ៍។ ខ្ញុំមិនស្គាល់អ្នកនិយាយទេ អ្នកនិយាយគឺនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយនៅក្នុងហាងកាហ្វេថាឈ្មោ[redacted] ជាអ្នកប្លន់សម្លាប់។ ខ្ញុំរក្សារបាយការណ៍របស់ខ្ញុំទុកដដែល។ ខ្ញុំមិនបានអោយឈ្មោះទាំង៧នាក់ ទៅដើមបណ្តឹងទេ ។ ចៅសង្កាត់បានអោយមកផ្សះផ្សា[redacted]មកផ្សះផ្សាជាមួយខាងជនរងគ្រោះកូនចៅសង្កាត់ឈ្មោះ[redacted]មានឈ្មោះក្នុងដែរ។ ឈ្មោះទាំង៧នាក់ បានគេចខ្លួនចេញពីមូលដ្ឋានទាំងអស់ ។

សាក្សីឈ្មោះ[redacted]នបំភ្លឺថា៖ នាងខ្ញុំជាម្តាយជនរងគ្រោះឈ្មោ[redacted]កើតហេតុខ្ញុំអត់ដឹងទេ នាងខ្ញុំដឹងថាកូនសំរាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ៦ថ្ងៃ ហើយក៏បានដឹកទៅវៀតណាមស្លាប់តាមផ្លូវ ព្យាបាលអស់ប្រហែល ៣000$ (បីពាន់ដុល្លាអាមេរិក) ការទាមទារសំណងជម្ងឺចិត្ត ទុកអោយកូនប្រុស[redacted]ជាអ្នកទាមទារ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ វេលាម៉ោងមួយរំលងអាធ្រាត មានមនុស្សពីរនាក់មកប្រាប់ខ្ញុំថា មានតែគ្រោះថ្នាក់ចរាចរ ប្លន់អ្វីខ្ញុំអត់ដឹងទេ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា៖ ចំពោះរបាយការណ៍សរសេរ ឈ្មោ[redacted] ជារបាការណ៍ផ្ទាល់ខ្លួនរបស់គាត់ គោរពចូលលោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលសំរោងក្រោម គឺមិនធ្វើជាលក្ខណៈទូទៅទេ។ លោកនាយប៉ុស្តិ៍អោយឈ្មោះ [redacted]សរសេររបាយការណ៍មួយផង [redacted]សរសេររបាយការណ៍មួយ ។ របាយការណ៍ដែលខ្ញុំសរសេរអោយ [redacted]តាមការរៀបរាប់របស់[redacted]។ យប់ថ្ងៃកើតហេតុ ខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំដេកនៅសាលាសង្កាត់ ខ្ញុំគ្រាន់តែបានសរសេររបាយការណ៍ផ្ទាល់ខ្លួនអោយគាត់ ពីព្រ[redacted]ងងឹតភ្នែកសរសេរមិនកើត។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា៖ នៅថ្ងៃទី ១០.១២.២០០៨ ខ្ញុំជាម្តាយឈ្មោះ[redacted] បានជួយរកក្មេងៗ ក្នុងភូមិជួយបោកស្រូវ ពេលនោះក្មេងឈ្មោះ[redacted]កបោកស្រូវតែគ្មានពាក់អាវទេ ខ្ញុំក៏ទៅយកអាវដៃវែង ពណ៌ពងមាន់ធ្នូតអោយទៅឈ្មោះ[redacted]ជួយបោកស្រូវ គឺបោករហូតដល់ម៉ោង ១១យប់ ទើបបោកស្រូវហើយ ពេលបោកស្រូវហើយឈ្មោះ[redacted]បានពាក់អាវរបស់កូនខ្ញុំឈ្មោះ [redacted] យកទៅបាត់ពុំឃើញយកមកអោយខ្ញុំវិញទេ ឯឈ្មោះ [redacted]ពុំឃើញនៅផ្ទះ ទើបតែនៅថ្ងៃទី ១៧.១២.២០០៨ សមត្ថកិច្ចនគរបាលសំរោងក្រោមមកផ្ទះខ្ញុំសួររឿងអាវ ដែលមានឈ្មោះកូនរបស់ខ្ញុំ ជាប់នឹងអាវនោះ គឺពិតជាអាវរបស់កូនខ្ញុំពិតប្រាកដមែន ប៉ុន្តែឈ្មោះ [redacted] ដែលជាអ្នកពាក់យកអាវកូនខ្ញុំ ចោលក្នុងព្រៃ នៅពេលប៉ូលីសចេញចាប់ក្នុងព្រៃ ។ ជនរងគ្រោះបានស្លាប់បាត់



Scanned by CamScanner

ហើយ មិនដឹងស្លាប់ថ្ងៃណាទេ ចំពោះកូនខ្ញុំឈ្មោះ[redacted]បានដើរជាមួយឈ្មោ[redacted]ឡើយ គឺកូនរបស់ខ្ញុំដេក នៅផ្ទះ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ ខ្ញុំមិនបានដឹងទេ ថ្ងៃកើតហេតុនោះ ក្រោយពីកើតហេតុហើយក្រោយបុណ្យ៧ថ្ងៃ ខ្ញុំបានទៅសួរសុខទុក្ខម្តាយជនរងគ្រោះឈ្មោះ [redacted] បន្ទាប់មកខ្ញុំបាននិយាយលេងជាមួយគាត់ថា តិចក្រែងលោមានអ្នកណាមកសំរបសំរួល តើមីងគិតយ៉ាងណា ហើយមីង [redacted] ឆ្លើយថា ស្រេចលើច្បាប់ទៅ ។ ពុំមានអ្នកណា ប្រើអោយខ្ញុំមកសួរទេ ខ្ញុំទៅក្នុងគោលបំណងសួរសុខទុក្ខតែប៉ុណ្ណោះ ក្រៅពីនេះ ខ្ញុំពុំបានដឹងរឿងអ្វីឡើយ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយថា៖ កាលពីថ្ងៃទី១១.១២.២០០៨ ខ្ញុំបានបើកឡានទៅ យកជនរងគ្រោះម្នាក់នៅសំរោងក្រោម ពេលទៅដល់មានប៉ូលីស បី បួននាក់នៅកន្លែងនោះ ខ្ញុំទៅដល់មិនបានឃើញបងប្អូន ជនរងគ្រោះទេ ខ្ញុំថាបើមិនឃើញបងប្អូនជនរងគ្រោះ ខ្ញុំមិនដឹកទៅទេ ពីព្រោះពេទ្យរបស់ខ្ញុំឯកជន ប៉ូលីសថាគាត់ទាក់ទង បងប្អូនគេរួចហើយ ។ ចំពោះជនរងគ្រោះខ្ញុំមិនដឹងថាត្រូវទឹងអ្វីទេ មនុស្សឃាត រឺ គ្រោះថ្នាក់ចរាចរខ្ញុំមិនដឹងទេ ហើយក៏ មិនបានសួរនាំអ្វីដែរ គ្រាន់តែបានដឹកជនរងគ្រោះមកដល់ពេទ្យរបស់ខ្ញុំតែប៉ុណ្ណោះ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted]ឆ្លើយថា៖ កាលពីថ្ងៃខែមិនចាំ ឆ្នាំ ២០០៨ ពេលកើតហេតុ ខ្ញុំ មិនបានឃើញផ្ទាល់ទេ គឺខ្ញុំដេកនៅផ្ទះខ្ញុំ មិនដឹងហេតុការឡើយ ។ នៅយប់នោះ ខ្ញុំលឺសូរគ្រាប់កាំភ្លើងពីរគ្រាប់ ខ្ញុំងើប ឡើងនៅម៉ោង ១H៣០ ខ្ញុំបើកអាយកូម ហើយលឺសំលេងតាមអាយកូមថា មានគ្រោះថ្នាក់ចរាច ។ ខ្ញុំមិនបានឃើញផ្ទាល់ ឡើយ យប់នោះខ្ញុំបានដើរទៅមើលស្នាមម៉ូតូ បុកគំនរថ្ម ។ គ្រោះថ្នាក់ចរាចរ រឺមនុស្សឃាដគិតទុកជាមុន ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែលឺតាមអាយកូមតែប៉ុណ្ណោះ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]ឆ្លើយថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ ខ្ញុំសំរាននៅផ្ទះ លេខ២២៥ ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ចំងាយពីកន្លែងកើតហេតុ ១៥ គីឡូម៉ែត្រ ។ ក្នុងរឿងនេះ ខ្ញុំមិនដឹងអ្វីទាំងអស់ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]ានឆ្លើយថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ វេលាម៉ោង ១H៣០ មានប៉ូលីសពីរនាក់បានទៅហៅប៉ូលីសនៅគោលដៅ ក្លែងថាអៃ (គោលដៅ២៤ម៉ោង) បានមកករាយការណ៍ថា មានគ្រោះថ្នាក់ចរាចរ មានមនុស្សដេកដួលនៅតាមផ្លូវ បុរសពីរនាក់នោះប្រាប់ថា ជួយទៅពិនិត្យមើល ហើយរកឡាន ពេទ្យផង ។ ក្រោយពីបានទទួល ខ្ញុំក៏ចេញមកដល់ជិត ២០០ ម៉ែត្រ ឃើញម៉ូតូពីរគ្រឿងចេញពីកន្លែងកើតហេតុ ខ្ញុំក៏ជិះម៉ូតូ ដេញតាមពីក្រោយ ជាមួយឈ្មោ[redacted]ទបាញ់ឡើងលើចំនួនពីរគ្រាប់ ហើយជននោះបានផ្តួល ម៉ូតូចោល ហើយខ្ញុំបានយកម៉ូតូនោះមករក្សាទុកនៅប៉ុស្តិ៍មួយថ្ងៃ ក៏ប្រគល់ម៉ូតូអោយក្រុមគ្រួសារជនរងគ្រោះវិញ ។ ពេល ដែលខ្ញុំដេញជនជាប់ចោទ គឺខ្ញុំមិនបានឃើញមុខ រឺស្គាល់មុខសញ្ញាទេ ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]ឆ្លើយថា៖កាលពីថ្ងៃទី ១១.១២.២០០៨ វេលាម៉ោង ១២H០០ នាទីរំលងអាធ្រាត នាងខ្ញុំអង្គុយក្នុងផ្ទះជាមួយប្តី ស្រាប់តែលឺសំលេងកាំភ្លើងជាច្រើនគ្រាប់ ពេលនោះខ្ញុំអើត មើលតាមរបងស្រាប់តែឃើញមនុស្សប្រុសពីរនាក់ រត់ពាក់អាវសកាត់មុខផ្ទះរបស់ខ្ញុំរត់ពីមុខទៅកើត ។ លុះស្អែកឡើង ក្មួយរបស់ខ្ញុំបានរើសអាវមួយនៅក្នុងព្រៃ យកមកអោយខ្ញុំមើល នៅជាមួយអាវមានឈ្មោ[redacted]មកប្អូនប្រុសនាងខ្ញុំ ឈ្មោះ[redacted]ាប់តែគាត់ប្រាប់ថា អាវដៃវែងនោះ គឺ[redacted] ាក់ដើម្បីជួយបោកស្រូវអោយគាត់ ។



Scanned by CamScanner

### សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

លោក [redacted] បានសន្និដ្ឋានថា៖ រឿងនេះជាបទល្មើសប្លន់សម្លាប់ ជនជាប់ចោទទាំង៧នាក់បានរៀបចំគំរោង។ លោក [redacted] អ្នកដឹងរឿងពិត ជនជាប់ចោទប្លន់រួចក៏យកម៉ូតូចោលនៅផ្លូវរថភ្លើង ហើយឪពុករប [redacted] ចចារសំរុះសំរួលសំណងជាមួយម្ដាយជនរងគ្រោះ។ មានដែកជន្លាសឡាននៅកន្លែងកើតហេតុ មានភស្តុតាងគ្រប់គ្រាន់ជាបទល្មើសប្លន់សម្លាប់ សុំអោយតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

### សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីស្ដាប់ការសួរដេញដោល និងពិនិត្យឯកសារសំណុំរឿងឃើញថា៖ មានរបាយការណ៍ពីរខុសគ្នា មួយជារបាយការណ៍គ្រោះថ្នាក់ចរាចរណ៍ និងរបាយការណ៍មួយទៀតជាអំពើឃាដកម្ម ដូច្នេះនាំអោយតុលាការពិបាកពិចារណាម្យ៉ាងវិញទៀត ពេលមានគ្រោះថ្នាក់កើតឡើង សមត្ថកិច្ចពុំបានធ្វើកំណត់ហេតុនៅកន្លែងកើតហេតុ។ តំណាងអយ្យការនៅតែតំកល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល តែសុំអោយតុលាការពិចារណាតាមច្បាប់។

### សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី ពេជ រតនា

លោក [redacted] ការអោយឈ្មោះ [redacted] នសន្និដ្ឋានថា៖ តាមការបញ្ជាក់របស់សមត្ថកិច្ចថា របាយការណ៍ថ្នាក់លើជាអ្នកបញ្ជាអោយធ្វើ។ លិខិតពេទ្យបញ្ជាក់ថា ពុំមានការវាយលើជនរងគ្រោះទេ រឿងនេះពុំមានភស្តុតាង និងសាក្សីឃើញនឹងភ្នែកទេ គឺពុំមានភស្តុតាងដើម្បីចោទប្រកាន់លើជនជាប់ចោទ ក៏ដូចជាកូនក្ដីខ្ញុំឡើយ សុំអោយតុលាការបញ្ឈប់ការចាប់ខ្លួន លើកលែងកូនក្ដីខ្ញុំបាទអោយមានសេរីភាពវិញ ។

### សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី [redacted]

លោក [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមការពិនិត្យលើរបាយការណ៍របស់សមត្ថកិច្ច មានរបាយការណ៍ពីរខុសគ្នា មួយជារបាយការណ៍គ្រោះថ្នាក់ចរាចរណ៍ របាយការណ៍មួយទៀតជារបាយការណ៍ឃាដកម្មគិតទុកជាមុន។ មានលិខិតចេញពីមន្ទីរពេទ្យថា ពុំមានការវាយសម្លាប់ទេ។ ដូចនេះ កូនក្ដីខ្ញុំបាទដែលជាជនជាប់ចោទ ពុំមានការពាក់ពន្ធ័ក្នុងអំពើគ្រោះថ្នាក់ចរាចរណ៍ ឬប្លន់សម្លាប់នេះទេ គ្រាន់តែជាវិមតិសង្ស័យតែប៉ុណ្ណោះ។ សុំអោយតុលាការមេត្តាលើកលែងកូនក្ដីខ្ញុំបាទឈ្មោះ [redacted] យមានសេរីភាព និងសុំបញ្ឈប់ការចាប់ខ្លួនកូនក្ដីខ្ញុំបាទ ចាប់ពីពេលប្រកាសសាលក្រមដោយក្ដីអនុគ្រោះ ។

### សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី [redacted]

លោក [redacted] នធ្វើសេចក្ដីសន្និដ្ឋានថា៖ ការបង្ហាញភស្តុតាងមានភាពផ្ទុយគ្នា ។ អង្គហេតុនេះ បណ្ដាលមកពីលោក [redacted] ដែលគាត់និយាយថា អ្នកនិយាយទំលាក់កំហុសលើជនជាប់ចោទគាត់មិនស្គាល់ទេ គាត់ស្គាល់ឈ្មោះជនជាប់ចោទតាមហាងកាហ្វេ ។ ភាគីកូនក្ដីខ្ញុំ មិនបានទៅចចារជាមួយគ្រួសារជនគ្រោះទេ ។ ជនរងគ្រោះស្លាប់ពុំមានការពាក់ពន្ធ័ដល់កូនក្ដីខ្ញុំបាទទេ លិខិតចេញពីមន្ទីរពេទ្យបានបញ្ជាក់ច្បាស់ថាពុំមានស្នាមវាយទេ ដូច្នេះពុំមានភស្តុតាង ដើម្បីផ្ដន្ទាទោសកូនក្ដីខ្ញុំបាទឡើយ។ តាមមាត្រា ៣២១ មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ សុំអោយតុលាការលើកលែងការចោទប្រកាន់ដល់កូនក្ដីខ្ញុំបាទដោយក្ដីអនុគ្រោះ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់ចម្លើយសាក្សី

ក្រោយពីបានស្ដាប់អំណានចម្លើយសាកស្សី



Scanned by CamScanner

77/4

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដី និងសំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យពិចារណាលើសំណុំរឿងចប់សព្វគ្រប់ហើយ

**យល់ឃើញថាៈ**

១.ពិតជាកើតមានអំពើមនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិត្រពាំងធ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១.១២.២០០៨ ប្រាកដមែន ។

២.អំពើដែលកើតមាននៅពេលវេលា និងទីកន្លែងដូចខាងលើ ពិតជាបានប្រព្រឹត្តឡើងដោយជនល្មើសមួយក្រុម បានស្ទាក់វាយជនរងគ្រោះឈ្មោះ[redacted]ណ្តាលអោយរបួសធ្ងន់ធ្ងរសន្លប់នៅនឹងកន្លែងកើតហេតុ ពេលដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្ររយៈពេល ០៦ថ្ងៃ ក៏ដឹកបន្តទៅព្យាបាលនៅប្រទេសវៀតណាម ជនរងគ្រោះក៏បានស្លាប់តាមផ្លូវ។ ក្រោយពេលជនល្មើសបានវាយជនរងគ្រោះបណ្តាលអោយសន្លប់រួចហើយ ក៏បានប្លន់យកម៉ូតូរបស់ជនរងគ្រោះ និងសំភារៈប្រើប្រាស់មួយចំនួនទៀត។ បន្ទាប់មកមានសមត្ថកិច្ចនគរបាល មកកន្លែងកើតហេតុ ក្រុមជនល្មើសក៏បានជិះម៉ូតូរបស់ជនរងគ្រោះ និងម៉ូតូផ្សេងទៀតរត់គេចខ្លួន សមត្ថកិច្ចក៏បានដេញតាម ដើម្បីឃាត់ជនល្មើស ជនល្មើសក៏បានផ្តួលម៉ូតូជនរងគ្រោះចោល រួចរត់គេចខ្លួនបាត់តែម្តង សមត្ថកិច្ចក៏បានស្រាវជ្រាវករណីនេះ រួចហើយបានចោទប្រកាន់លើឈ្មោះ[redacted]

៣.តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]បញ្ជាក់ថាៈ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ថ្ងៃកើតហេតុថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ ខ្លួនផឹកស្រាជាមួយឈ្មោះ[redacted] ៦ល្ងាចរហូតដល់ម៉ោង ៩យប់ នៅផ្[redacted]ួចបន្តផឹកនៅឃ្លាំងជាមួយឈ្មោ[redacted]តដល់ម៉ោង ១២យប់ គឺមានឈ្មោះ[redacted] ពុំបានផឹកជាមួយទេ ពេលផឹកស៊ីក៏ដេកជជែកគ្នានៅកន្លែងឃ្លាំងនោះ លឺផ្ទុះកាំភ្លើងចំងាយប្រហែល៤០០ម៉ែត្រ លុះព្រឹកឡើងទើបដឹងថា ជនរងគ្រោះឈ្មោះ[redacted] ត្រូវគេប្លន់ ខ្លួនលឺគេថា ខ្លួនគឺជាជនដៃដល់ក្នុងករណីប្លន់នេះ ក៏រត់គេចខ្លួនទៅខេត្តរតនៈគិរី លុះត្រលប់មកវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

៤.តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]វជាប្រពន្ធជនរងគ្រោះបំភ្លឺថាៈ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ មានប៉ូលីសសំរោងក្រោមពីរនាក់ បានមកប្រាប់ថា ប្តីរបស់ខ្លួនត្រូវចោរប្លន់វាយរបួសធ្ងន់ធ្ងរណាស់ ខ្លួនបានយកប្តីទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្ររយៈពេល ០៦ថ្ងៃ ទើបស្លាប់ ហើយបានពិនិត្យឃើញមានស្នាមវាយនឹងដែកជន្លាសឡានលើត្រចៀករហូតដល់ក្បាលផុងគ្រប់កន្លែង ខ្លួនប្តឹងទាមទារសំណងជំងឺចិត្តចំនួន ២០ម៉ឺនដុល្លា ពី[redacted]និងសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

៥.សាក្សី [redacted]បញ្ជាក់ថាៈ ថ្ងៃកើតហេតុទី ១១.១២.២០០៨ ខ្លួនពុំបានឃើញ ឬនៅនឹងកន្លែងកើតហេតុទេ ឈ្មោ[redacted]ជាប៉ូលីសបុស្តិ៍អោយខ្លួនសរសេរពាក្យបណ្តឹងមានឈ្មោះ[redacted] ។ ឈ្មោះ[redacted]បានទូរស័ព្ទមកខ្លួនអោយជួយនិយាយជាមួយ ឈ្មោះ[redacted]បពន្ធជនរងគ្រោះអោយដកពាក្យបណ្តឹងទទួលសំណងវិញ ហើយប្រាប់[redacted]ចាំសួរប្អូនសិន។



Scanned by CamScanner

៦.សាក្សីឈ្មោះ [redacted] ញ្ជាក់ថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ វេលាម៉ោង ១យប់ ខ្លួនកំពុងយាមប្រចាំការនៅប៉ុស្តិ៍ ស្រាប់តែមនុស្សពីរនាក់បានទៅប្រាប់មានមនុស្សដួលសន្លប់។ ពេលនោះខ្លួនទៅជាមួយឈ្មោះ [redacted] ,ឈ្មោះ [redacted], និងឈ្មោ [redacted] ដលមានចម្ងាយប្រហែល ២០០ម៉ែត្រ ឃើញជនសង្ស័យមួយក្រុមមិនដឹងចំនួនប៉ុន្មាននាក់ ក្នុងនោះមានជនសង្ស័យពីរនាក់ជិះម៉ូតូ C១២៥ ពណ៌ខ្មៅ ចេញពីកន្លែងកើតហេតុយ៉ាងលឿនចំណែកបក្សពួកផ្សេងទៀត រត់ចេញពីកន្លែងកើតហេតុ ពួកខ្លួនដេញតាមហៅអោយឈប់ និងបានបាញ់ឡើងលើអោយឈប់ តែជនសង្ស័យបានផ្តួលម៉ូតូC១២៥ចោល ខ្លួនក៏យកម៉ូតូមកទុកនៅប៉ុស្តិ៍។ ថ្ងៃទី ១៤.១២.២០០៨ វេលាម៉ោង ១១ ឈ្មោះ [redacted] បានយកក្រដាសសរសេរដៃ មកឃើញមានឈ្មោះជនសង្ស័យទាំង៧នាក់អោយមើល ចំពោះអាវជាភស្តុតាងគឺពុំបានយកមកទេ។

៧.សាក្សីឈ្មោះ [redacted] បញ្ជាក់ថា៖ខ្លួនពុំចាំថ្ងៃ ខែ កើតហេតុ តែពេលយប់ម៉ោងប្រហែលមួយ ខ្លួនមកពីបង់ត្រីជួបជនរងគ្រោះដួលលើគន្លងថ្នល់ ប៉ុរុងទៅជួយ ស្រាប់តែជនពីរនាក់ស្រែកអោយខ្លួនងាកចេញ ខ្លួនក៏បានទៅរាយការណ៍អោយប៉ូលីស។ ខ្លួនពុំស្គាល់ជនពីរនាក់នោះទេ ប៉ុន្តែខ្លួនឃើញជិះម៉ូតូស្ទាស។ ម៉ូតូឃើញដួលជិតគន់រថ្មប្រហែល ៣ ទៅ ៤ម៉ែត្រ។

៨.សាក្សីឈ្មោ [redacted] ភ្លឺថា៖ ខ្លួនឃើញប៉ូលីស ហើយពួគេនិយាយថាប៉ូលីសឈ្មោ [redacted] ជាអ្នកបាញ់ ហើយចោរបានផ្តួលម៉ូតូចោល ប៉ូលីសក៏យកម៉ូតូទៅទុកនៅប៉ុស្តិ៍។ ឃើញឈ្មោះ [redacted] និងឈ្មោះ [redacted] ជិះម៉ូតូមកពីខាងជើង ហើយឈ្មោះ [redacted] ស្រែកថាជនរងគ្រោះស្លាប់បាត់ហើយ។

៩.សាក្សីឈ្មោះ [redacted] បញ្ជាក់ថា៖ យប់ថ្ងៃកើតហេតុខ្លួនពុំចាំទេ គឺឈ្មោ [redacted] នៅផ្ទះចាប់ត្រីជាមួយខ្លួនរហូតដល់ម៉ោង ១១យប់ ទើបខ្លួនអោយទៅផ្ទះ ប្រហែលកន្លះម៉ោងឮសូរគ្រាប់កាំភ្លើង។

១០.សាក្សីឈ្មោ [redacted] ញ្ជាក់ថា៖ យប់កើតហេតុ ពួកខ្លួនផឹកស្រាបៀរជាមួយឈ្មោះ [redacted] នៅផ្ទះខ្លួន ពេលយប់បន្តិចក៏ទៅហូបស្រាបន្តនៅផ្ទះឈ្មោះ [redacted] រហូតដល់ម៉ោងប្រហែល ១ យប់។ ម៉ោងប្រហែល ១២ យប់ លឺសូរគេបាញ់ពីផ្ទះខ្លួនហួបចុកទៅកន្លែងកើតហេតុប្រហែល ១០០ម៉ែត្រ ពួកខ្លួនពុំបានចេញទៅណាទេ។

១១.សាក្សីឈ្មោះ [redacted] បញ្ជាក់ថា៖ពេលកើតហេតុខ្លួននៅផ្ទះ ព្រឹកឡើងឮគេនិយាយ ពីមាត់មួយទៅមាត់មួយថាឈ្មោះ [redacted] ជាអ្នកធ្វើសកម្មភាពប្លន់ម៉ូតូជនរងគ្រោះ ខ្លួនជិះល្បាតតាមផ្ទះ ក៏បាត់ឈ្មោះខាងលើអស់។ ឈ្មោះ [redacted] ជាអ្នកប្រាប់ឈ្មោ [redacted] រឿងពីឈ្មោះទាំង៧នាក់ ដើម្បីបានលុយដោះស្រាយថ្ងៃពេទ្យ។ ចម្លើយសាក្សីឈ្មោះ [redacted] ឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ខ្លួនពុំស្គាល់អ្នកនិយាយនៅហាងកាហ្វេទេ គឺនិយាយតៗគ្នាថាឈ្មោះ [redacted] ជាអ្នកប្លន់ម៉ូតូជនរងគ្រោះ ខ្លួនពុំបានអោយឈ្មោះទាំង៧នាក់នោះទៅដើមបណ្តឹងទេ ចៅសង្កាត់បានអោយឈ្មោះ [redacted] មកចរចារសំណងជាមួយដើមបណ្តឹងឈ្មោះ ប៉ុញ ប៉ក់ ដើម្បីផ្សះផ្សារឿងសំណង ព្រោះចៅសង្កាត់មានកូនឈ្មោះ [redacted] ចម្លើយសាក្សីស៊ីសង្វាក់ថា៖ ពិតជាបានលឺគេនិយាយថាឈ្មោះជនជាប់ចោទទាំង៧នាក់ដូចខាងលើ ប្លន់ម៉ូតូជនរងគ្រោះរួចរត់គេចខ្លួនពីផ្ទះទាំងអស់គ្នា។

១២.សាក្សីឈ្មោ [redacted] បញ្ជាក់ថា៖ខ្លួនជាម្តាយរបស់ឈ្មោ [redacted] កាលពីយប់ថ្ងៃទី ១០.១២.២០០៨ ខ្លួនបានរកក្មេងៗជួយបោកស្រូវ ក៏បានយកអាវដៃវែង ពណ៌ពងមាន់ធ្មួតអោយឈ្មោះ [redacted] ពាក់បោកស្រូវ ហើយបាត់រហូត ពុំឃើញយកអាវមកអោយវិញ។ ឈ្មោ [redacted] ពុំឃើញនៅផ្ទះដែរ។ កូនរបស់ខ្លួន ពុំបានដើរជាមួយឈ្មោះ



Scanned by CamScanner

[redacted]ទ ។ ចម្លើយសាក្សីនេះបញ្ជាក់ឈ្មោះ[redacted]គជាបានពាក់អាវរបស់កូនខ្លួនឈ្មោះ[redacted]របោះអាវនោះចោល រួចបានគេចខ្លួនបាត់ ។

១៣.សាក្សីឈ្មោះ [redacted]បញ្ជាក់ថា៖ ខ្លួនពិតជាបានទៅសួរសុខទុក្ខម្តាយជនរងគ្រោះឈ្មោះ[redacted]បន្ទាប់ពីកើតហេតុ៧ថ្ងៃ បាននិយាយលេងជាមួយម្តាយជនរងគ្រោះ តិចក្រែងលោមានអ្នកណាមកស់របស់រូល។ គឺបញ្ជាក់ពីចេតនារបស់ឈ្មោះ[redacted]ដែលទៅចរចារឿងសំណងជាមួយជនរងគ្រោះ ដូចសាក្សី[redacted]នបញ្ជាក់មែន ។

១៤.ចម្លើយសាក្សីឈ្មោះ[redacted]និងឈ្មោះ[redacted]ញ្ជាក់ពួកខ្លួនពុំបានឃើញហេតុការណ៍ និងដឹងពីមូលហេតុនៃការស្លាប់របស់ជនរងគ្រោះទេ ។

១៥.សាក្សីឈ្មោះ [redacted]បានបញ្ជាក់ថា៖ កាលពីថ្ងៃទី ១១.១២.២០០៨ បានឆ្លើយប្រហាក់ប្រហែលគ្នានិងសាក្សីឈ្មោះ [redacted]ក្រោយពីបានទទួលដំណឹងថា មានជនរងគ្រោះដួលនៅកន្លែងកើតហេតុ ពួកខ្លួនក៏ទៅចម្ងាយជិត ២០០ ម៉ែត្រ ក៏ឃើញជនល្មើសជិះម៉ូតូពីរចេញពីកន្លែងកើតហេតុ រួចពួកខ្លួនក៏ដេញ ឈ្មោះ [redacted]បានបាញ់អោយឈប់ រួចហើយជនល្មើសក៏ផ្តួលម៉ូតូចោលរត់គេចខ្លួន ម៉ូតូដែលជនល្មើសផ្តួលជារបស់ជនរងគ្រោះ។ សាក្សីឈ្មោះ[redacted]ថាឃើញជនរងគ្រោះដួលសន្លប់ លើគំនរថ្ម ខ្លួនបំរុងចូលទៅជួយ ជនល្មើសស្រែកអោយខ្លួនងាកចេញ បញ្ជាក់អោយឃើញថា ក្រុមជនល្មើសពិតជាបានប្រព្រឹត្តអំពើប្លន់សម្លាប់ជនរងគ្រោះ ដើម្បីយកទ្រព្យសម្បត្តិជនរងគ្រោះ ហើយអំពើប្លន់សម្លាប់នេះ គឺជាបទល្មើសឃាដកម្មគិតទុកជាមុន ។

១៦.សាក្សីឈ្មោះ[redacted]នបញ្ជាក់ថា៖ ថ្ងៃទី១១.១២.២០០៨ វេលាម៉ោង១២យប់ ខ្លួនលឺសូរសំលេងបាញ់កាំភ្លើង អើតមើលតាមរបងឃើញមនុស្សពីរនាក់ រត់ពាក់អាវសកាត់មុខផ្ទះរបស់ខ្លួនពីទិសដៅពីមុខផ្ទះទៅកើត ។ ស្អែកឡើងក្មួយៗរបស់ខ្លួនរើសអាវមួយក្នុងព្រៃ មានឈ្មោះ[redacted]បប្អូនរបស់ខ្លួនឈ្មោះ [redacted]កឈ្មោះ [redacted] ស្រាប់តែគាត់ប្រាប់ថា អាវដៃវែងនេះគឺអោយឈ្មោះ[redacted]ពាក់បោកស្រូវ ។

១៧.ជនជាប់ចោទឈ្មោះ [redacted]ឆ្លើយបដិសេធថា៖ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការទេ ខ្លួនរត់ទៅខេត្តរតនៈគិរីដោយសារលឺគេនិយាយថា ខ្លួននិងបក្សពួកជាជនដៃដល់។ ចម្លើយដោះសារនេះពុំអាចអោយតុលាការជឿបានទេ ដោយពុំមានភស្តុតាងដោះបន្ទុកច្បាស់លាស់ ផ្ទុយទៅវិញជនជាប់ចោទឈ្មោះ[redacted] ពិតជាបានគេចខ្លួនមួយរយៈ [redacted] ពិតជាបានរត់គេចខ្លួនពីមូលដ្ឋានរហូតដល់សព្វថ្ងៃ។ បន្ទាប់ពីពេលកើតហេតុ សមត្ថកិច្ចឈ្មោះ[redacted]និងឈ្មោះ[redacted]ដេញតាមជនល្មើស ជនល្មើសពីរនាក់ក៏ផ្តួលម៉ូតូជនរងគ្រោះចោល រួចហើយសាក្សីឈ្មោះ [redacted]ឃើញជនល្មើសរត់ពាក់អាវសកាត់មុខផ្ទះរបស់ខ្លួន អាវនោះមានឈ្មោះ[redacted]ពលប្អូនរបស់ខ្លួនសួរនាំ ឪពុករបស់[redacted]ឆ្លើយថាអាវនោះអោយឈ្មោះ[redacted]ខ្ចីពាក់។ ចម្លើយនេះស៊ីសង្វាក់នឹងចម្លើយសាក្សីឈ្មោះ [redacted]ដែលបញ្ជាក់ថា៖ ខ្លួនជាម្តាយរបស់ឈ្មោះ[redacted] ពិតជាបានអោយឈ្មោះ [redacted]ខ្ចីពាក់អាវរបស់កូនខ្លួនឈ្មោះ [redacted] ជួយបោកស្រូវ កាលពីយប់ថ្ងៃទី ១០.១២.២០០៨ រួចក៏បាត់ខ្លួន។ ចម្លើយនេះបញ្ជាក់ អាវដែលរើសបាននេះ ពិតជាឈ្មោះ[redacted]បានពាក់មែន ។ ភស្តុតាងស៊ីសង្វាក់មួយទៀតគឺដែកជន្ទាសឡានដែលឈ្មោះ[redacted]សបាននៅកន្លែងកើតហេតុ ។

១៨.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ៖ [redacted]ហៅ រាជ ភេទប្រុស អាយុ ១៩ ឆ្នាំ [redacted] មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិត្រពាំងថ្លង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី



Scanned by CamScanner

១១.១២.២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ដូចតំណាងអយ្យការបានចោទប្រកាន់ប្រាកដមែន ។

១៩.អំពើរបស់ជនជាប់ចោទមានចេតនាប្លន់សម្លាប់ជនរងគ្រោះ គឺមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសឃាតកម្មគិតទុកជាមុន ដែលច្បាប់តំរូវអោយផ្តន្ទាទោស ។

២០.ជនជាប់ចោទឈ្មោះ [redacted] គប្បីពិចារណាពីស្ថានសំរាល ។

២១.ដើមបណ្តឹងឈ្មោះ [redacted] ទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលចំនួន ២០ម៉ឺន ដុល្លារអាមេរិក គប្បីពិចារណាតាមច្បាប់ ។

## ហេតុដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ

## វិនិច្ឆ័យសេចក្តី

I. ផ្តន្ទាទោសឈ្មោះ

ក. [redacted] ហៅ រាជ ភេទប្រុស អាយុ ១៥ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្នាំ (ប្រាំពីរឆ្នាំ)

ខ. [redacted] ភេទប្រុស អាយុ ២០ឆ្នាំ

គ. [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ

ឃ. [redacted] ភេទប្រុស អាយុ ២៤ ឆ្នាំ

ង. [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ

ច. [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ

ឆ. [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ១៥ ឆ្នាំ (ដប់ប្រាំឆ្នាំ) ពីបទ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងថ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១.១២.២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

II. បង្គាប់អោយចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] ទៅពន្ធនាគារ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

III. បង្គាប់អោយឈ្មោះ [redacted] និងអាណាព្យាបាលរបស់ឈ្មោះ [redacted] រួមគ្នាសងជម្ងឺចិត្ត និងការខូចខាតទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ៣០.០០០.០០០៛ (សាមសិបលានរៀល) ការទាមទារលើសពីនេះ បដិសេធ ចោល ។

IV. វត្ថុតាងចាប់យកមាន អាវដៃវែងចំនួន០១ ពណ៌ពងមាន់ធ្លុត និងដែកជន្ទាសចំនួន០១ ត្រូវរឹបអូសបំផ្លាញចោល ។

V. សាលក្រមនេះ ជំនុំជម្រះថ្ងៃទី ០១.៤.២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២.៥.២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខានិងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 12 ខែ 5 ឆ្នាំ 2011

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner